**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបញ្ចូលមណ្ឌលសភាពាណិជ្ជកម្ម ខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ ជាមណ្ឌលសភាពាណិជ្ជកម្មតែមួយ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២ និងមាត្រា១៥ ស្តីពីច្បាប់សភាពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-អនុក្រឹត្យលេខ ២៦ អនុក្រ-បក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តសៀមរាប

-អនុក្រឹត្យលេខ ៥៥ អនុក្រ-បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តឧត្តរមានជ័យ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ស ម្រេ ច

**មាត្រា១.-** ដោយខេត្តឧត្តរមានជ័យ ពុំមានលក្ខខណ្ឌៈសម្បត្តិគ្រប់គ្រាន់ ក្នុងការបង្កើតសភាពាណិជ្ជកម្មដោយ ឡែករបស់ខ្លួន និង ដោយយោងតាមមាត្រា១ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម រាជរដ្ឋាភិបាលសម្រេចបញ្ចូលសភាពាណិជ្ជកម្មខេត្តឧត្តរមានជ័យ ទៅក្នុងមណ្ឌលសភាពាណិជ្ជកម្មខេត្តសៀមរាប ។

**មាត្រា២.-** វិសាលភាពសភាពាណិជ្ជកម្មខេត្តសៀមរាប ត្រូវបានលាតសន្ធឹងទូទាំងខេត្តសៀមរាប និង ខេត្តឧត្តរមានជ័យ ។

**មាត្រា៣.-** ទីតាំងការិយាល័យប្រតិបត្តិនៃមណ្ឌលសភាពាណិជ្ជកម្មខេត្តទាំងពីរខាងលើ ត្រូវស្ថិតនៅទីរួមខេត្តសៀមរាប ។

**មាត្រា៤.-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តសៀមរាប អភិបាលខេត្តឧត្តរមានជ័យ ប្រធានសភាពាណិជ្ជកម្មកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៦ ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-សាលារាជធានី-ខេត្ត
-សភាពាណិជ្ជកម្មកម្ពុជា
-ដូចមាត្រា៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ